00335596

E39/4/2

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 02 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក)

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT RE
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception 01 / 06 / 2009
ម៉ោង (Time/Heure): 15:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent du dossier: SANN RADA

| | |
|---|---|
| **សំណុំរឿងព្រហ្មទណ្ឌលេខ៖** | ០០១/១៨-០៧-២០០៧-អវតក/អជសដ |
| **ដាក់តម្កល់ជូន:** | អង្គជំនុំជម្រះសាលាដំបូង |
| **កាលបរិច្ឆេទដាក់ឯកសារ៖** | ០១/០៦/២០០៩ |
| **ភាគីអ្នកតម្កល់៖** | សហមេធាវីការពារក្តីលោក កាំង ហ្គេកអ៊ាវ |
| **ភាសា៖** | ភាសាដើមជាភាសាបារាំង |
| **ប្រភេទឯកសារ៖** | **សាធារណៈ:** |

---

## កំណត់សម្គាល់របស់មេធាវីការពារនៅលើសំណុំឯកសាររបស់តុលាការយោធា

---

**<u>អ្នកដាក់តម្កល់:</u>**

**សហមេធាវីជនជាប់ចោទ**

**កាំង ហ្គេកអ៊ាវ ហៅ ឌុច**

មេធាវី **ការ សាវុត្ថ**

មេធាវី Marie-Paule Canizares

មេធាវី François ROUX

**<u>ចម្លងជូន:</u>**

**<u>ការិយាល័យសហព្រះរាជអាជ្ញា</u>**

លោកស្រី ជា លាង

លោក Robert PETIT

**<u>ចម្លងជូន:</u>**

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

មេធាវី **គង់ ពិសី**

មេធាវី **ហុង គីមសួន**

មេធាវី **យុង ផានិត**

មេធាវី **គីម ម៉េងឃី**

មេធាវី **ម៉ុច សុវណ្ណារី**

មេធាវី Silke STUDZINSKY

មេធាវី Martine JACQUIN

**<u>តម្កល់ជូន:</u>**

**<u>អង្គជំនុំជម្រះសាលាដំបូង</u>**

ចៅក្រម **និល ណុន** ជាប្រធាន

លោកស្រីចៅក្រម **Silvia CARTWRIGHT**

ចៅក្រម **យ៉ា សុខន**

ចៅក្រម **Jean-Marc LAVERGNE**

ចៅក្រម **ធូ មណី**

មេធាវី Philippe CANNONE

មេធាវី **ទី ស្រីនណា**

មេធាវី Pierre Olivier SUR

មេធាវី Alain WERNER

មេធាវី Brianne McGONIGLE

មេធាវី Annie DELAHAIE

មេធាវី ElizabethRABESANDRATANA

មេធាវី Karim KHAN

00335597

E39/4/2

## <u>គោរពជូនអង្គជំនុំជម្រះសាលាដំបូង</u>

១. យោងលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៩ [1] និង សេចក្តីសម្រេចចុះថ្ងៃទី ២៨ ឧសភា ឆ្នាំ ២០០៩ [2] មេធាវីការពារក្តី ក្រោយពីបានធ្វើការពិនិត្យទៅលើ ខ្លឹមសារនៃឯកសារនានារបស់តុលាការយោធា សូមធ្វើកំណត់សម្គាល់របស់ខ្លួនដូចតទៅ:

២. មេធាវីការពារក្តីយល់ឃើញថាសំណុំឯកសារនានារបស់តុលាការយោធាបានបង្ហាញយ៉ាងច្បាស់ថា ការឃុំខ្លួនបណ្តោះអាសន្នរបស់លោក **កាំងហ្កេកអ៊ាវ** ហៅ **ឌុច** ត្រូវបានធ្វើឡើងដោយតុលាការយោធាក្នុងគោលដៅរង់ចាំឱ្យមានការបង្កើត អ.វ.ត.ក. និងបន្ទាប់មកបញ្ជូនឈ្មោះនេះទៅជំនុំជម្រះនៅចំពោះមុខតុលាការមួយនេះ។ ជាមួយគ្នានេះដែរ សំណុំឯកសារអស់ទាំងនេះក៏បានលាតត្រដាងដោយមិនអាចប្រកែកបានថាការសម្រេចឃុំខ្លួនរបស់ អ.វ.ត.ក.ទៅលើរូបលោក **កាំងហ្កេកអ៊ាវ** គឺជាការបន្តរការឃុំខ្លួនបណ្តោះអាសន្នដែលការឃុំខ្លួននេះបានធ្វើឡើងពីដំបូងទីដោយតុលាការយោធា។

៣. ជាក់ស្តែង ផ្អែកលើសំណុំឯកសាររបស់តុលាការយោធា មេធាវីការពារយល់ឃើញថា ចំណុចទីមួយ ចាប់តាំងពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៩៩ មក ការសម្រេចចោទប្រកាន់លើឈ្មោះ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** គឺត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញានៃតុលាការយោធា [3] ក្រោមអង្គហេតុនានាដែលមានលក្ខណៈដូចគ្នាទៅនឹងអង្គហេតុដែលប្រកាន់យកដោយអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. ផងដែរ គឺការចោទ ប្រកាន់ទៅលើអង្គហេតុនៃ ទង្វើរបស់ជនជាប់ចោទដែលបានប្រព្រឹត្តក្នុងនាមជាប្រធានមន្ទីរ ស-២១ កាលពីសម័យកម្ពុជាប្រជាធិបតេយ្យ [4]។

---

[1] “ *សេចក្តីសម្រេចពន្យារយៈពេលកំណត់ ដើម្បីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទនៅក្រៅឃុំ*” អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩, E39/4 ។

[2] សេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ដែលតម្រូវឱ្យគូរភាគីដាក់កំណត់សម្គាល់របស់ខ្លួនស្តីពីសំណុំឯកសាររបស់តុលាការយោធាឱ្យបានយូរបំផុតត្រឹមថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៩។

[3] សូមពិនិត្យមើលឯកសារ E52/4.3 និង E52/4.8 ។

[4] ពីថ្ងៃទី ១០ ឧសភា ១៩៩៩ រហូតដល់ថ្ងៃទី ៣០ កក្កដា ២០០៧, ការដាក់ក្រោមនីតិវិធីចោទប្រកាន់ និងឃុំខ្លួនបណ្តោះអាសន្នទៅ លើលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញានៃតុលាការយោធា និងក្រោមបញ្ជារបស់ចៅក្រមស៊ើបអង្កេត ចំពោះបទល្មើសដែលបានប្រព្រឹត្តប្រឆាំងនឹងសន្តិសុខជាតិ (សូមពិនិត្យមើលឯកសារ E52/4.3, E52/4.8, E52/4.9)

៤. ចំណុចទីពីរ មេធាវីការពារសូមលើកឡើងថា ចាប់តាំងពីខែ កុម្ភៈ ឆ្នាំ ២០០២ មក លោក **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ត្រូវបានដាក់ក្រោមនីតិវិធីចោទប្រកាន់ និងឃុំខ្លួនបណ្ដោះអាសន្ន ស្របតាមបទបញ្ញត្តិនៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ និងជាពិសេសត្រូវបានចោទប្រកាន់ពីបទបង្កឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្របតាមមាត្រា ៥ និង ៣៩ នៃច្បាប់នេះ [5] និងពីបទបង្កឧក្រិដ្ឋកម្មសង្គ្រាម ស្របតាមមាត្រា ៦ និង ៨ នៃច្បាប់នេះ ផងដែរ [6]។

៥. ទីបញ្ចប់ តាមរយៈដីកាចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៨ ដែលមេធាវីការពារបានបញ្ជាក់ជូនអង្គជំនុំជម្រះរួចមកហើយ [7] ចៅក្រមស៊ើបអង្កេតបានសម្រេចបញ្ចប់សមត្ថកិច្ចរបស់តុលាការយោធា ដែលតុលាការនេះបានសម្រេចទទួលស្គាល់សមត្ថកិច្ចរបស់ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មអស់ទាំងនោះ។

៦. យោងលើមូលហេតុដូចបានអះអាងទាំងអម្បាលម៉ានខាងលើនេះ មេធាវីការពារយល់ឃើញថា វានឹងមានហេតុផលសមស្របក្នុងការធ្វើសំណើរសុំទៅអង្គជំនុំជម្រះសាលាដំបូងនាពេលចេញសាលក្រម ក្នុងករណីដែលមានការផ្ដន្ទាទោស លើជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ដើម្បីសុំឲ្យអង្គជំនុំជម្រះមេត្តាទទួលយកថេរៈវេលាសរុបនៃការឃុំខ្លួនបណ្ដោះអាសន្នលើជនជាប់ចោទរូបនេះ ដោយគិតចាប់តាំងពីថ្ងៃចាប់ខ្លួន រូបគាត់ នាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃប្រកាសសាលក្រម ធ្វើជាលក្ខខណ្ឌបន្ធូបន្ថយទោសដែលនឹងត្រូវសម្រេចទៅលើជនជាប់ចោទរូបនេះ។

---

ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (សូមពិនិត្យមើលឯកសារ E52/4.22, E52/4.26, E52/4.33, E52/4.34, E52/4.35, E52/4.46) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (សូមពិនិត្យមើលឯកសារ E52/4.47, E52/4.48, E52/4.50, E52/4.51, E52/4.52, E52/4.53 និង E52/4.54) និងឧក្រិដ្ឋកម្មសង្គ្រាម ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលដែលទទួលបានការការពារជាអន្តរជាតិ (សូមពិនិត្យមើលឯកសារ E52/4.57, E52/4.59, E52/4.60, E52/4.61 និង E52/4.63)។

[5] សូមពិនិត្យមើលឯកសារ E52/4.47, E52/4.48, E52/4.50, E52/4.51, E52/4.52, E52/4.53 និង E52/4.54។

[6] សូមពិនិត្យមើលឯកសារ E52/4.57, E52/4.59, E52/4.60, E52/4.61, E52/4.63។

[7] សូមពិនិត្យមើលឯកសារ E52/4.66 និងប្រតិចារឹក ថ្ងៃសវនាការ លេខ ៣ ថ្ងៃទី ១ ខែមេសា ឆ្នាំ ២០០៩ ទំព័រទី ២៦ បន្ទាត់ទី ១២, E/7.1 (ជាភាសាបារាំង) និងពិនិត្យមើល *“អំណះអំណាងបន្ថែមដែលបានលើកដោយមេធាវីការពារក្ដីដើម្បីផ្ដល់ការគាំទ្រដល់ការស្នើសុំរបស់ខ្លួនទាក់ទងនឹងការដាក់ទោស”* ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩, E39/3 កថាខណ្ឌទី ៤។

00335599

E39/4/2

៧. ចាប់តាំងពីពេលនេះតទៅ មេធាវីការពារយល់ឃើញថាការឃុំខ្លួនជនជាប់ចោទមិនអាចត្រូវបានបន្តទៀតឡើយ ដោយសារការឃុំខ្លួននេះមានរយៈពេលហួសពីរយៈពេលឃុំខ្លួនដែលកំណត់ដោយវិធាននៃច្បាប់ជាតិនិងអន្តរជាតិ ហើយមិនតែប៉ុណ្ណោះវាហួសពីកម្រិតនានា (ស្តង់ដា) ដែលកំណត់ដោយយុត្តិសាស្ត្រ ជាពិសេសយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងរបស់គណៈកម្មាធិការសិទ្ធិមនុស្ស [8]។

## ហេតុដូច្នេះ

៨. ស្នើសុំដោះលែងជនជាប់ចោទជាបន្ទាន់ ដោយដាក់ជនជាប់ចោទស្ថិតក្រោមវិធានការត្រួតពិនិត្យរបស់តុលាការ និងសន្តិសុខ [9]។

---

[8] សូមពិនិត្យមើល “ដីកាឃុំខ្លួនជនដែលជាប់ឃុំឃាំងនៅប្រទេសលីបង់ ក្នុងសំណុំរឿងនៃការវាយប្រហារទៅលើលោកនាយករដ្ឋមន្ត្រី Rafic HARIRI និងបុគ្គលដទៃទៀត” ចេញដោយចៅក្រមសម្របសម្រួលសំណុំរឿងនៃតុលាការពិសេសសម្រាប់ប្រទេសលីបង់ ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៩។ ជាពិសេស សូមអានកថាខណ្ឌទី ២២ នៃដីកានេះ ដែលយោងលើយុត្តិសាស្ត្រសមស្របមួយ ដូចមានបញ្ជាក់ក្នុងលេខយោងផ្នែកខាងក្រោមនៃទំព័រទី ៧ ដូចតទៅ: “គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានរំលឹកជារឿយៗថា “ការឃុំខ្លួនមុនការប្រកាសសាលក្រមគឺត្រូវធ្វើតែក្នុងករណីពិសេសប៉ុណ្ណោះ” (គណៈកម្មាធិការសិទ្ធិមនុស្ស រឿងក្តី Hill *ប្តឹងទល់នឹងប្រទេស អេស្ប៉ាញ* លិខិតជូនដំណឹងលេខ ៥២៦ /១៩៩៣ ចុះថ្ងៃទី ២ ខែមេសា ឆ្នាំ ១៩៩៧ កថាខណ្ឌទី ១២.៣)។ម្យ៉ាងទៀត គណៈកម្មាធិការសិទ្ធិមនុស្សនេះ ក៏បានលើកឡើងផងដែរថា ការឃុំខ្លួននេះមិនត្រឹមតែ ត្រូវមានលក្ខណៈស្របច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែមាន “ហេតុផលសមស្រប និងចាំបាច់” ។ (គណៈកម្មាធិការសិទ្ធិមនុស្ស, រឿងក្តី Van Alphen ប្តឹងទល់នឹងប្រទេស ហុល្លង់ លិខិតជូនដំណឹងលេខ ៣០៥ /១៩៨៨ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩០ កថាខណ្ឌទី ៥.៨ និង គណៈកម្មាធិការ សិទ្ធិមនុស្ស, រឿងក្តី Spakmo ប្តឹងទល់នឹងប្រទេស ន័រវែស លិខិតជូនដំណឹងលេខ ៦៣១ /១៩៩៥ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ កថាខណ្ឌទី ៦.៣)។ ជាមួយគ្នានេះដែរ តាមរយៈយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ៖ “ខ្លឹមសារនៃកថាខណ្ឌទី ៣ (របស់ មាត្រា ៥ នៃអនុសញ្ញា) (...) សម្តៅទៅលើសិទ្ធិក្នុងការមានសេរីភាព ដោយរង់ចាំការកាត់ទោសពីបទព្រហ្មទណ្ឌ (...)។ កម្មវត្ថុនៃមាត្រា ៥ កថាខណ្ឌទី ៣ គឺមានគោលដៅធ្វើការដោះលែងជាបណ្តោះអាសន្ន ចាប់ពីពេលដែលការឃុំខ្លួននោះលែងមានហេតុផលសមស្របទៀតហើយ (...)។ ក្នុងទស្សនៈវិស័យនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុប យល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន នឹងត្រូវបានចាត់ទុកថាជាវិធានការមួយចាំបាច់ តែក្នុងករណីដែលវិធានការផ្សេងៗទៀតត្រូវបានគេមើលឃើញថាគ្មានលក្ខណៈគ្រប់គ្រាន់” (CEDH, សាលដីកា Lelièvre ប្តឹងទល់នឹងប្រទេស បែលស៊ិក ចុះថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០៨ កថាខណ្ឌទី ៩៧)” ។

[9] សូមពិនិត្យមើលអត្ថបទក្នុងលេខយោងខាងលើនេះ ត្រង់ទំព័រទី ១៦។

# សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | | |
|---|---|---|---|
| | សហមេធាវីទាំងពីរ<br><br>មេធាវី **ការ សាវុត្ថ**<br><br><br><br>មេធាវី **Marie-Paule Canizares** | ភ្នំពេញ | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |